រក្សាសិទ្ធិ © ពត៌មាន :
© ២០០៩ Project WorldReach © ២០០៩ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :
Project WorldReach PWR ™
474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

047KH01A-01

ការអធិស្ឋានទូលអង្វររបស់ក្រុមជំនុំ



កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល

៤៧

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™

ទូលសូមឱ្យព្រះជាម្ចាស់ជួយអោយក្រុមជំនុំរបស់អ្នក អាចរៀបចំការអធិស្ឋានទូលអង្វរប្រកបដោយប្រសិទ្ធិភាព ។

ការព្យាយាមអធិស្ឋាន

បន្ទាប់មក ព្រះយេស៊ូមានព្រះបន្ទូលជាប្រស្នាពន្យល់សាវ័កអោយដឹងថា ត្រូវតែអធិស្ឋានជានិច្ច មិនត្រូវរសាយចិត្តឡើយ÷

«នៅក្នុងក្រុងមួយ មានចៅក្រមម្នាក់ជាមនុស្សមិនកោតខ្លាចព្រះ-ជាម្ចាស់ ហើយមិនកោតក្រែងនរណាឡើយ ។ មានស្ត្រីមេម៉ាយម្នាក់នៅក្នុងក្រុងនោះដែរ ។ គាត់តែងមកអង្វរចៅក្រមថា "សូមលោករកយុត្តិធម៌អោយនាងខ្ញុំផង" ។ ប៉ុន្តែ ចៅក្រមមិនព្រមកាត់ក្តីអោយភ្លាមៗទេ លោកចេះតែពន្យារពេលយ៉ាងយូរ ។ ក្រោយមក លោកនឹកក្នុងចិត្តថា "ទោះបីអញមិនកោតខ្លាចព្រះ-ជាម្ចាស់ មិនកោតក្រែងនរណាក៏ដោយ ក៏អញត្រូវតែកាត់ក្តីអោយស្ត្រីមេម៉ាយនេះដែរ ព្រោះគាត់ចេះតែមករំអុកអញគ្រប់ពេលវេលា ។ បើអញមិនកាត់ក្តីអោយគាត់ទេ មុខជាគាត់មករំខានអញមិនចេះចប់មិនចេះហើយ !" » ។

កំណត់ចំណាំ :

© Project WorldReach © SEAN

កំណត់ចំណាំ :

ព្រះអម្ចាស់មានព្រះបន្ទូលបន្ថែមទៀតថា÷ *«ចូរពិចារណាពាក្យរបស់ចៅក្រមដ៏អាក្រក់នេះចុះ ។ ចំណង់បើព្រះជាម្ចាស់វិញ ព្រះអង្គរឹតតែរកយុត្តិធម៌ឱ្យអស់អ្នក ដែលព្រះអង្គបានជ្រើសរើស ហើយដែលអង្វរព្រះអង្គទាំងយប់ទាំងថ្ងៃ ព្រះអង្គគ្រាន់តែបង្អង់ប៉ុណ្ណោះ ។ ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា ព្រះអង្គនឹងរកយុត្តិធម៌អោយគេ ក្នុងរយៈពេលដ៏ខ្លី ។ ប៉ុន្តែ ពេលបុត្រមនុស្សមកដល់ តើលោកឃើញមនុស្សមានជំនឿនៅលើផែនដីនេះឬទេ ? »* ។

(លូកា ១៨:១-៨)

ព្រះជាម្ចាស់ចង់អោយយើងព្យាយាមទូលសូមព្រះអង្គ ដូចដែលស្ត្រីមេម៉ាយទូលសូមដែរ ។

ទោះបីព្រះអង្គដែលជាព្រះធំខ្ពស់បំផុត អាចធ្វើអ្វីៗគ្រប់យ៉ាងក៏ដោយ ក៏ព្រះអង្គមានព្រះហឫទ័យអោយយើងចូលរួមចំណែក ក្នុងកិច្ចការរបស់ព្រះអង្គដែរ ។ យើងចូលរួមចំណែកក្នុងកិច្ចការរបស់ព្រះអង្គ ដោយស្វែងរកព្រះហឫទ័យព្រះអង្គ និង អធិស្ឋានទូលសូមដោយជំនឿ ។

ព្រះអម្ចាស់យេស៊ូមានបន្ទូលថា÷ *«ហេតុនេះហើយបានជាខ្ញុំសុំប្រាប់អ្នករាល់គ្នាថា អ្វីក៏ដោយ អោយតែអ្នករាល់គ្នាអធិស្ឋានសុំ ចូរជឿថាអ្នករាល់គ្នាបានទទួលហើយ នោះព្រះជាម្ចាស់នឹងប្រទានអោយអ្នករាល់គ្នាជាពុំខាន»* ។

(ម៉ាកុស ១១:២៤)

បើយើងព្យាយាមអធិស្ឋាន ដោយជំនឿរឹងមាំ នោះយើងនឹងឃើញចំលើយ និង កិច្ចការធំៗរបស់ព្រះជាម្ចាស់ ។

តាមព្រះបន្ទូលព្រះយេស៊ូ ព្រះជាម្ចាស់ដ៏នៅអស់កល្ប ដែលមានគ្រប់ព្រះចេស្តា ឆ្លើយតប :

☐ ស្របទៅតាមជំនឿរបស់យើង ។

☐ ស្របទៅតាមចំណូលចិត្តរបស់យើង ។

ព្រះជាម្ចាស់ឆ្លើយតបនឹងពាក្យទូលសូមរបស់យើង បើសិនជាយើងទូលសូមដោយបន្ទាបខ្លួន ដោយសេចក្តីស្រឡាញ់ និង ដោយជំនឿ ។ ព្រះជាម្ចាស់សព្វព្រះហឫទ័យអោយយើងចូលរួមក្នុងកិច្ចការរបស់ព្រះអង្គ ។ យើងអាចចូលរួមជាមួយព្រះអង្គ ដោយអធិស្ឋាន និង មានជំនឿ ។ ព្រះជាម្ចាស់មានប្រាជ្ញាញាណដែលគ្មានកំណត់ ដូច្នេះ ព្រះអង្គច្រើនតែមិនធ្វើសកម្មភាពទេ លុះត្រា

កិច្ចការដែលត្រូវអនុវត្ត

- អ្នកត្រូវធ្វើជាគំរូអំពីរបៀបព្យាយាមអធិស្ឋាន ដែលផុសចេញពីក្នុងជំរៅចិត្តរបស់អ្នក ។
- ព្រះអង្គដឹកនាំពួកគេ ឱ្យចេះអធិស្ឋានទៀងទាត់ និង ស្មោះត្រង់ រួមជាមួយក្រុមគ្រួសារ និង មិត្តភក្តិរបស់ពួកគេ ។
- បង្រៀនក្រុមជំនុំអ្នកពីសារៈសំខាន់នៃការអធិស្ឋាន ។
- យកយោបល់ទាំងប៉ុន្មាន ដែលសមរម្យសំរាប់ស្ថានភាពរបស់អ្នក ទៅអនុវត្តនៅក្នុងពេលប្រជុំអធិស្ឋានរបស់អ្នក ។
- លើកទឹកចិត្តសមាជិករបស់ក្រុមជំនុំ អោយចេះអធិស្ឋានឱ្យគ្នាទៅវិញទៅមក ។

ព្រះពរដែលបានមកពីការអធិស្ឋាន

នៅពេលដែលយើងអធិស្ឋាន គឺយើងចូលរួមធ្វើកិច្ចការ ដើម្បីពង្រីកព្រះរាជ្យរបស់ព្រះជាម្ចាស់ និង ធ្វើឱ្យសំរេចតាមព្រះហឫទ័យរបស់ព្រះអង្គនៅលើផែនដីនេះ ។ ការចូលរួមធ្វើកិច្ចការដ៏ប្រសើរនេះ នឹងនាំអោយមនុស្សជឿ និង កែប្រែចិត្តគំនិត ហើយនឹងនាំឱ្យអ្នកឈឺបានជាសះស្បើយ និង ជីវិតយើងផ្លាស់ប្តូរបន្តិចម្តងៗ ទៅតាមលក្ខណៈរបស់ព្រះគ្រីស្ត ។ ម៉្យាងទៀត ការអធិស្ឋាននាំអោយសាតាំង និង បក្សពួករបស់វាបរាជ័យ រីឯព្រះជាម្ចាស់វិញ ទទួលសិរីរុងរឿង តាមរយៈព្រះអម្ចាស់យេស៊ូនៃយើង (ម៉ាថាយ ៦:៩-១៥) ។

តែយើងទូលសូមព្រះអង្គ ស្របតាមព្រះហឫទ័យរបស់ព្រះអង្គទើបព្រះអង្គធ្វើ ។ ហេតុនេះហើយបានជាក្រុមជំនុំដែលចេះប្រតិបត្តិតាមព្រះគ្រីស្ត និង ចង់រីកចំរើនជាបន្ត តែងតែអធិស្ឋានជាប់ជានិច្ច ។ ការអធិស្ឋានជាអំណរ និង កិត្តិយសដ៏ធំសំរាប់ក្រុមជំនុំ ។

យើងអធិស្ឋានដោយរបៀបផ្សេងៗ ដូចជាអធិស្ឋានម្នាក់ឯង អធិស្ឋានជាមួយក្រុមគ្រួសារ និង អធិស្ឋានជាមួយអ្នកជឿឯទៀត ។ ម៉្យាងទៀត យើងអធិស្ឋានក្នុងក្រុមជំនុំ ឬ ក្នុងការប្រជុំអធិស្ឋាន ។

គោលបំណងសំខាន់បំផុតរបស់កូនសៀវភៅនេះ គឺលើកទឹកចិត្តមនុស្សអោយអធិស្ឋានដោយស្មោះត្រង់ និង ដោយឫទ្ធានុភាពទាំងពេលអធិស្ឋានម្នាក់ឯង ទាំងពេលអធិស្ឋានជាមួយក្រុមជំនុំ ។ កូនសៀវភៅសិក្សានេះ មិនមែនមានបំណងផ្តល់របៀបពិស្តារដែលសាំញ៉ាំច្រើនអំពីការអធិស្ឋានទេ គឺមានបំណងផ្តល់ឧទាហរណ៍អំពីរបៀបអធិស្ឋានខ្លះ និង អញ្ជើញអ្នកទុកឱ្យព្រះវិញ្ញាណដ៏វិសុទ្ធដឹកនាំអ្នក ក្នុងការអធិស្ឋាន តាមគំរោងស្របតាមព្រះគម្ពីរសម្ពន្ធមេត្រីថ្មី (ម៉ាថាយ ១៨:១៩-២០) ។

យើងត្រូវទុកចិត្តលើការឆ្លើយតបរបស់ព្រះជាម្ចាស់ល្អបំផុត សំរាប់យើងដែរ ទោះបីជាចំលើយនោះអាចខុសពីការសង្ឃឹមរបស់យើងក៏ដោយ ។

ព្រះជាម្ចាស់ជ្រាបដឹងពីអ្វី ដែលប្រសើរសំរាប់ស្ថានភាពនិមួយៗ និង សំរាប់មនុស្សម្នាក់ៗ ។

យើងត្រូវអធិស្ឋានដើម្បីអ្វីខ្លះ ?

ការសរសើរតម្កើងព្រះជាម្ចាស់ :

- យើងអធិស្ឋានដើម្បីសរសើរតម្កើងព្រះជាម្ចាស់ និង អរព្រះគុណព្រះអង្គ ។

ការទូលអង្វរ :

- យើងអធិស្ឋានទូលអង្វរសំរាប់អស់អ្នកណាដែលត្រូវទទួលជឿព្រះយេស៊ូ ហើយសំរាប់អស់អ្នកណាដែលមានសេចក្តីត្រូវការ ។

ក្រុមជំនុំ :

- ដើម្បីអោយមានការកែប្រែចិត្តគំនិត និង ការស្រែកឃ្លានខាងព្រលឹងវិញ្ញាណ (២ រាជក្សត្រ ៧:១៣-១៤) ។

- ☐ ការអានព្រះគម្ពីរ ឬ អធិស្ឋានវែងពេកដែលបណ្តាលអោយធុញទ្រាន់ ។
- ☐ ការច្រៀង ឬ ពិភាក្សាពីសំណូមពរអធិស្ឋានច្រើនពេក ។
- ☐ ការប្រជុំអូសបន្លាយវែងពេក ។ គួរតែបញ្ចប់មុនដែលអ្នកចូលរួមធុញទ្រាន់ ។

ដំបូន្មានសំរាប់អ្នកដឹកនាំ

អ្នកដឹកនាំ ដែលវៃឆ្លាត ត្រូវ :

- ត្រៀមខ្លួនទទួលការដឹកនាំពីព្រះវិញ្ញាណដ៏វិសុទ្ធ ។
- រៀបចំការប្រជុំអធិស្ឋានអោយបានល្អ ។
- ប្រាប់អ្នកចូលរួមអោយដឹងច្បាស់ថា ត្រូវអធិស្ឋានអំពីអ្វី ។
- អធិស្ឋានខ្លួនឯងយ៉ាងខ្លី និង ប្រើឃ្លាស្រួលៗ ។ល។ ។

© Project WorldReach © SEAN

ឧបសគ្គដែលធ្វើអោយរាំងស្ទះដល់ការអធិស្ឋាន

សូមគូសសញ្ញានៅពីមុខចំណុចទាំងឡាយ ដែលអ្នកមានបំណងចៀសវាងមិនអោយកើតមាននៅក្នុងការប្រជុំអធិស្ឋាន និង ដែលត្រូវកែតម្រូវនៅក្នុងក្រុម ឬ ក្រុមជំនុំដែលអ្នកដឹកនាំ :

- ☐ គំនិតទិតៀន (ឧទាហរណ៍ ការនិយាយប្រឆាំងនឹងក្រុមជំនុំផ្សេងទៀត ឬ រអ៊ូអំពីកិច្ចការក្នុងក្រុមជំនុំ ។ល។) ។
- ☐ ទិតៀនអ្នកដទៃ ដោយការអធិស្ឋាន ។ មនុស្សខ្លះប្រើការអធិស្ឋានជាក្រុម ដើម្បីនិយាយទិតៀនមនុស្សម្នាក់ទៀត ។ ការធ្វើដូចនេះ មើលទៅដូចជាមានភាពវិសុទ្ធ ក៏ប៉ុន្តែ ការប្រើពេលអធិស្ឋាន ជាឱកាសសំរាប់និយាយដើមគ្នា ជាការមិនសមរម្យទេ ។
- ☐ ការរំខាននៅពេលអធិស្ឋាន (ដូចជា ការធ្វើអោយឮសូរក្តុងក្តាំង ពេលរកកន្លែងអង្គុយ ដោយសារមកដល់យឺតពេល ពេក ឬ ការជជែកគ្នា ពេលកំពុងអធិស្ឋាន ។ល។) ។

- ដើម្បីអោយមានការចាក់បង្ហូរព្រះវិញ្ញាណដ៏វិសុទ្ធមក ដើម្បីប្រទានឫទ្ធានុភាព (កិច្ចការ ៤:២៣-៣១) ។
- ដើម្បីអោយមានឯកភាព (យ៉ូហាន ១៧:២០-២១, កិច្ចការ ១:១៤, ២:១) ។
- សំរាប់គ្រូគង្វាល និង អ្នកដឹកនាំ (អេភេសូ ៦:១៩-២០) ។
- សំរាប់កិច្ចការបំរើ និង ជីវិតខាងព្រលឹងវិញ្ញាណរបស់ក្រុមជំនុំ (កាឡាទី ៦:២, អេភេសូ ១:១៧-១៩) ។
- សំរាប់ការប្រជុំថ្វាយបង្គំ (១ កូរិនថូស ១៤:២៦) ។

ការផ្សាយដំណឹងល្អក្នុងពិភពលោក :

- ដើម្បីឱ្យអ្នកដែលមិនទាន់ជឿ បានសង្គ្រោះ (១ ធីម៉ូថេ ២:១-៤) ។
- ដើម្បីអោយមានអ្នកផ្សព្វផ្សាយដំណឹងល្អ (ម៉ាថាយ ៩:៣៨) ។



- ដើម្បីអោយទ្វារបើកចំហ (កូឡូស ៤:២-៣) ។
- ដើម្បីអោយមានផលផ្លែ (២ ថេស្សាឡូនិក ៣:១) ។
- ដើម្បីអោយមានការផ្សព្វផ្សាយដំណឹងល្អគ្រប់ទីកន្លែង ដែលមិនទាន់ឮព្រះនាមព្រះគ្រីស្តនៅឡើយ (រ៉ូម ១៥:២០-២១) ។
- សំរាប់ក្រុមមនុស្ស និង ប្រទេសដែលមិនទាន់ទទួលដំណឹងល្អអំពីព្រះយេស៊ូគ្រីស្ត (រ៉ូម ១០:១៤-១៥) ។

រដ្ឋអំណាចរបស់គ្រប់ជាតិសាសន៍ (១ ធីម៉ូថេ ២:១-៤) :

- ដើម្បីអោយពួកគេថ្វាយខ្លួន ។
- ដើម្បីអោយមានឱកាសល្អសំរាប់ផ្សាយដំណឹងល្អ ។
- ដើម្បីអោយមានសេចក្តីសុខសាន្ត ដោយសារក្រិត្យវិន័យសុចរិតរបស់ព្រះគម្ពីរ ។

ក្រុមគ្រួសារ (អេភេសូ ៥:២១-៦:៤) :

- ដើម្បីអោយមានសេចក្តីស្រឡាញ់ ។
- ដើម្បីអោយមានការរួបរួមគ្នា ។
- ដើម្បីអោយមានការតស៊ូ ។

ដែលព្រះជាម្ចាស់បានធ្វើ ។ ធ្វើដូចនេះ លើកទឹកចិត្តពួកអ្នកជឿអំពីព្រះហឫទ័យសប្បុរសរបស់ព្រះជាម្ចាស់ ។

ត្រូវផ្លាស់ប្តូររបៀបអធិស្ឋាន ដើម្បីចៀសវាងកុំអោយមានទម្លាប់អធិស្ឋាន ដោយរបៀបតែមួយរហូត ដែលប្រកាសឃ្លាដដែលៗ ចាំមាត់ ដោយមិនគិត ។

ត្រូវប្រើផែនទី ពត៌មានប្រចាំថ្ងៃតាមវិទ្យុ ឬ សាពត៌មានសំរាប់ធ្វើការអធិស្ឋានទូលអង្វរអោយទីកន្លែងផ្សេងៗទៀត នៅក្នុងពិភពលោក ដែលមានសង្គ្រាម អំពើហិង្សា អំពើអយុត្តិធម៌ ឬ ប្រជាជនដែលមិនទាន់ជឿលើព្រះគ្រីស្ត (អ្នកអាចប្រើកូនសៀភៅ ទី ២៧ «ទៅផ្សព្វផ្សាយដំណឹងល្អដល់គ្រប់ជាតិសាសន៍ ») ។ សូមអធិស្ឋានសំរាប់អ្នកដែលធ្វើកិច្ចការបំរើនៅកន្លែងទាំងអស់នោះ ។

ត្រូវប្រើបទភ្លេង ដែលសមរម្យសំរាប់ការថ្វាយបង្គំ ការសរសើរតម្កើង និង ការអរព្រះគុណ ។

ឧទាហរណ៍អំពីរបៀបអធិស្ឋាន ដូចជា :

- អធិស្ឋានក្នុងចិត្ត ។
- អធិស្ឋានដោយអានអត្ថបទព្រះគម្ពីរ គឺអានវគ្គទំនុកតម្កើងខ្លះ ឬ សេចក្តីអធិស្ឋានរបស់ព្រះជាម្ចាស់ ឬ វគ្គណាមួយផ្សេងទៀត ។ សមាជិកទាំងអស់អាចអានរួមគ្នា ឬ អានឆ្លាស់ជាមួយអ្នកដឹកនាំក៏បានដែរ ។
- អធិស្ឋានដោយច្រៀងសរសើរតម្កើងព្រះជាម្ចាស់ គឺច្រៀងឆ្លាស់ជាមួយនឹងការនិយាយអធិស្ឋាន ។
- អធិស្ឋានជារង្វង់មូល (អង្គុយ ឬ ឈរ ឬ កាន់ដៃគ្នា) ។

អធិស្ឋានតាមរបៀបផ្សេងៗ ដើម្បីកុំឱ្យមានការច្រំដែល

ទុកអោយព្រះវិញ្ញាណដ៏វិសុទ្ធ បង្ហាញអ្នកអោយចេះឆ្នៃប្រឌិតរបៀបអធិស្ឋានផ្សេងៗ ។ ការអធិស្ឋានដែលគ្រាន់តែជាការនិយាយដដែលៗ តាមទម្លាប់ នឹងបាត់បង់ភាពស្វាហាប់ និង បណ្តាលឱ្យបែកអារម្មណ៍ ។ ទុកអោយមនុស្សចែកចាយចំលើយរបស់ព្រះជា-ម្ចាស់ចំពោះការអធិស្ឋាន ដើម្បីឱ្យអ្នកចូលរួមស្គាល់ដឹងពីកិច្ចការ

អ្នកដែលមានសេចក្តីត្រូវការ (កាឡាទី ១:១៩, យ៉ាកុប ៥:១៣-១៦) ដូចជា :

- អ្នកជំងឺ ។
- អ្នកខ្សោយ ឬ អ្នកពិការ ។
- អ្នកទោស ។
- អ្នកស្រែកឃ្លាន ។
- អ្នកគ្មានការងារធ្វើ ។

ការអធិស្ឋានត្រូវមានសកម្មភាពអមជាមួយ ។ ឧទាហរណ៍ នៅពេលដែលយើងអធិស្ឋានសំរាប់មនុស្សអត់ឃ្លាន យើងត្រូវផ្តល់ឱ្យគេទៅតាមលទ្ធភាពរបស់យើង ។ ជួនកាលព្រះជាម្ចាស់ប្រើយើងដើម្បីឆ្លើយតបនឹងការអធិស្ឋានរបស់យើងផ្ទាល់ ។

ឱកាសអធិស្ឋានផ្សេងៗ

នេះជាឧទាហរណ៍អំពីការជួយមនុស្សអោយអធិស្ឋាន ដែលក្រុមជំនុំខ្លះអនុវត្ត តែការសំខាន់ គឺជាការលើកទឹកចិត្តអោយគេអធិស្ឋានតាមការដឹកនាំរបស់ព្រះជាម្ចាស់ ។

- ការប្រជុំអធិស្ឋានរួមគ្នា ពេលព្រលឹមជារៀងរាល់ថ្ងៃ មុននឹងចេញទៅធ្វើការ ។
- ការប្រជុំអធិស្ឋានរួមគ្នាប្រចាំអាទិត្យ តាមផ្ទះ ឬ កន្លែងផ្សេងទៀត ដែលស្រួលជួបជុំគ្នា ។
- មុនពេលថ្វាយបង្គំ គឺអធិស្ឋានសំរាប់ពួកអ្នក ដែលដឹកនាំ ឬ ជួយក្នុងការប្រជុំថ្វាយបង្គំ ។
- ទុកពេលច្រើនសំរាប់អធិស្ឋាន ក្នុងពេលថ្វាយបង្គំ ។
- «ការអធិស្ឋានបណ្តាក់គ្នា» ដែលសមាជិកព្រមព្រៀងគ្នាអធិស្ឋានបន្តគ្នាតាមម៉ោងកំណត់ ដើម្បីឱ្យមានការអធិស្ឋានជាប់ជាបន្តក្នុងរយៈពេល ២៤ ម៉ោង នៅថ្ងៃកំណត់ណាមួយ (បើសិនជាក្រុមជំនុំមានសមាជិកច្រើន គេអាចធ្វើ «ការអធិស្ឋានបណ្តាក់គ្នា» ក្នុងរយៈពេលមួយអាទិត្យក៏បានដែរ) ។
- អធិស្ឋានពេញមួយយប់ ឬក៏មួយរយៈនៅពេលយប់ ។
- អធិស្ឋាន និង តមអាហារពេញមួយថ្ងៃ (អាចអធិស្ឋាន និង តមអាហារដូចនេះច្រើនថ្ងៃ) ។

- ☐ បើជាក្រុមជំនុំធំ ត្រូវធ្វើក្រុមអធិស្ឋានតូចៗ ។
- ☐ នៅពេលដែលមានអ្នកជឿថ្មី ដែលមិនទាន់ចេះអធិស្ឋាន ត្រូវអធិស្ឋានខ្លីៗ ស្រួលៗសិន ។ អ្នកដឹកនាំខ្លះ និយាយដើមឃ្លាបន្តិច រួចទុកឱ្យអ្នកជឿថ្មីម្នាក់បញ្ចប់ឃ្លា ។ (ឧទាហរណ៍ អ្នកដឹកនាំនិយាយថា÷ «ព្រះបិតា កូនអរគុណចំពោះ...» ហើយអ្នកជឿថ្មីម្នាក់បញ្ចប់ឃ្លា ដោយពាក្យរបស់គេផ្ទាល់ថា÷ «...ចំពោះសុខភាពល្អរបស់ខ្ញុំ ។» ឬក៏អ្នកដឹកនាំនិយាយថា÷ «ព្រះបិតា កូនសូម...» ហើយអ្នកជឿថ្មីម្នាក់បញ្ចប់ឃ្លា ដោយពាក្យរបស់គេផ្ទាល់ថា÷ «...ឱ្យព្រះអង្គនាំប្រពន្ធកូនទូលបង្គំអោយទទួលជឿព្រះអង្គផង»)។ របៀបអធិស្ឋានស្រួលមួយទៀត គឺអញ្ជើញអ្នកចូលរួមអោយសរសេរសេចក្តីអធិស្ឋានខ្លីមួយនៅផ្ទះ រួចយកមកអាន នៅពេលប្រជុំអធិស្ឋាន ។

☐ ចំពោះពួកអ្នកជឿថ្មី សុំធ្វើគំរូនៃការអធិស្ឋានស្រួលៗ ដែលនាំអោយពួកអ្នកជឿថ្មីអាចអធិស្ឋានតាមបាន ។ ឧទាហរណ៍ អញ្ជើញអ្នកចូលរួមឱ្យអធិស្ឋានមួយឃ្លាម្នាក់ សំរាប់សេចក្តីត្រូវការណាមួយ ។ សូមកុំបង្ខំមនុស្ស ដែលមិនទាន់ចេះអធិស្ឋាន អោយអធិស្ឋានឮៗ នៅមុខគេឯង ។

☐ នៅពេលដែលអ្នកមើលឃើញថា មនុស្សត្រូវការឈ្នះលើនិស្ស័យចាស់របស់ខ្លួន សុំទុកឱកាសអោយគេចុះចូលព្រះ-ជាម្ចាស់ ។ គឺថា អាចអោយគេលន់តួសារភាពអំពើបាបរបស់គេក្នុងចិត្ត និង ទូលសូមឱ្យព្រះជាម្ចាស់ដឹកនាំ និងប្រទានឫទ្ធានុភាពដល់ការរស់នៅរបស់គេ ។

☐ មុនពេលប្រជុំថ្វាយបង្គំ អ្នកដឹកនាំត្រូវសរសេរប្រធានបទនិមួយៗខាងក្រោមនេះ លើសន្លឹកក្រដាសធំៗ (ប្រធានបទមួយលើក្រដាសមួយសន្លឹក) : « ការសរសើរតម្កើង » « ការអធិស្ឋានទូលសូម » « ការអធិស្ឋានទូលអង្វរអោយមនុស្សឯទៀត » និង « ការអរព្រះគុណ » ។ នៅក្រោមប្រធាន-បទនិមួយៗទាំងនោះ ឱ្យសមាជិកសរសេរសំណូមពរអធិស្ឋានផ្សេងៗ ។ រួចបិទក្រដាសទាំងនោះលើជញ្ជាំង ហើយណែនាំក្រុមឱ្យអធិស្ឋាន អំពីសំណូមពរអធិស្ឋានទាំងនោះ ។

• កត់ឈ្មោះពួកអ្នកមិនទាន់ជឿយកទៅកន្លែងប្រជុំ ដើម្បីទូលអង្វរឱ្យពួកគេបានសង្គ្រោះ ឬ បានជាសះស្បើយ ។ យើងអាចនាំមនុស្សទៅជាមួយ ដើម្បីអធិស្ឋានឱ្យពួកគេផ្ទាល់ ។

គំនិតយោបល់អ្នកផ្ទាល់ :

_____

_____

_____

_____

ណែនាំអោយអ្នកជឿចូលរួមអធិស្ឋាន

នៅក្នុងចំណោមយោបល់ខាងក្រោមនេះ សូមគូសសញ្ញា នៅពីមុខយោបល់ដែលអ្នកចង់យកទៅអនុវត្ត ដើម្បីជំរុញទឹកចិត្តក្រុមជំនុំរបស់អ្នក អោយចេះអធិស្ឋានដោយជំនឿ :

☐ ពន្យល់យ៉ាងខ្លីអំពីរបៀបអធិស្ឋាន ស្របទៅតាមអត្ថបទព្រះគម្ពីរមួយ ។ បើអ្នកប្រើវគ្គគម្ពីរណាមួយខាងក្រោមនេះ សូមសរសេរក្រោមវគ្គគម្ពីរនោះ អំពីខ្លឹមសារនៃការអធិស្ឋានដែលមាននៅក្នុងវគ្គគម្ពីរនោះ ជាពាក្យអ្នកផ្ទាល់ :

☐ ម៉ាថាយ ១៨:១៨-២០

☐ ម៉ាកុស ១១:២២-២៦

☐ លូកា ១១:១-១៣

☐ លូកា ១៨:១-៨

☐ កិច្ចការ ១:១៤ ព្រមជាមួយនឹង ២:១

☐ កិច្ចការ ៤:២៣-៣១

☐ ១ ធីម៉ូថេ ២:១-៤

☐ មុននឹងអធិស្ឋាន ត្រូវសុំឱ្យអ្នកណាម្នាក់ពន្យល់ពីមូលហេតុដែលយើងអធិស្ឋាន ហើយនិងពីមូលហេតុ ដែលយើងជឿថា ព្រះជាម្ចាស់នឹងឆ្លើយតបចំពោះការអធិស្ឋានរបស់យើង (ព្រះបន្ទូលសន្យាក្នុងព្រះគម្ពីរ ។ល។) ។

☐ ចំពោះអ្នកជឿដែលមានបទពិសោធន៍ច្រើនជាង ត្រូវទុកឱ្យអ្នកជឿម្នាក់ៗអធិស្ឋាន តាមការដឹកនាំរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ។ ឧទាហរណ៍ ស្តេចសាឡូម៉ូនអធិស្ឋាន (២ រាជ-ក្សត្រ ៦:១៤-៤២) សំរាប់រយៈពេលមួយ ។ ពេលដែលទ្រង់អធិស្ឋានចប់ ព្រះជាម្ចាស់ធ្វើការអស្ចារ្យជាច្រើន ។ ស្តេចនេះអធិស្ឋាន ពេលដែលព្រះវិញ្ញាណដ៏វិសុទ្ធប៉ះពាល់ចិត្តទ្រង់ ។ ដូច្នេះ យើងអាចទុកឱកាសថ្វាយព្រះវិញ្ញាណ-ដ៏វិសុទ្ធជំរុញអ្នកណាម្នាក់អោយអធិស្ឋានសំរាប់សេចក្តីត្រូវការណាមួយ ។